**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានព័ត៌មាន និង សោតទស្សន៍**
**នាយកដ្ឋានមណ្ឌលព័ត៌មាន**

**គោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រី**

**កម្មវត្ថុ** : របាយការណ៍ស្តីពីការចុះផ្សាយអត្ថបទដែលមានចំណងជើងថា ***" ហ៊ុនសែនព្រមានទាំងផ្លូវណាក៏ដោយមានទាំងប្រើយោធាទប់ទល់បណ្តឹងបរិហាកេរ្តិ៍ និងស្នើបរទេសខ្លះគួរតែដកខ្លួនចេញពីកម្ពុជា "*** របស់សារព័ត៌មានខ្មែរម្ចាស់ស្រុក ឆ្នាំទី៣ លេខ៤៦៧ ចេញផ្សាយថ្ងៃព្រហស្បតិ៍ ទី១៣ ខែសីហា ឆ្នាំ២០០៩។

នាយកដ្ឋានមណ្ឌលព័ត៌មាន សូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា សារព័ត៌មានខ្មែរម្ចាស់ស្រុក ចេញផ្សាយអត្ថបទរបស់ខ្លួនខ្វះការទទួលខុសត្រូវ តាមហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើម ដោយសរសេរចុះផ្សាយកែបន្លំពាក្យសំដីរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងសុន្ទរកថា នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ក្នុងឱកាសប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថា... *"លោក ហ៊ុន សែន ក៏បានព្រមានដល់បរទេសនានានៅប្រទេសកម្ពុជា ដែលមិនអញ្ជើញក៏ត្បិតថា គួរដកខ្លួនចេញពីកម្ពុជាវិញ ពីព្រោះកម្ពុជា មានលទ្ធិប្រជាធិបតេយ្យហើយ "..." លោកហ៊ុន សែន ក៏បានព្រមានដល់បណ្តាប្រទេសមួយចំនួនដែលតែងតែលូកដៃចូលក្នុងរឿងផ្ទៃក្នុងរបស់ប្រទេសកម្ពុជានោះថា អោយដកខ្លួនចេញពីកម្ពុជាវិញ ពីព្រោះកម្ពុជាមានលទ្ធិប្រជាធិបតេយ្យគ្រប់គ្រាន់ហើយ"* ...។

ការពិតសំដីរបស់សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា... *"ពួកអ្នកខាងក្រៅ មិនថាជនជាតិខ្មែរ ឬបរទេសនោះទេ ត្រូវដកខ្លួនអោយឆាប់ អ្នកឯងភ្លើ អ្នកឯកល្ងង់ អ្នកឯងមិនចេះច្បាប់ អ្នកឯងទទួលស្គាល់តែសិទ្ធិពួកប្រឆាំង ប៉ុន្តែអ្នកឯងមិនដែល ទទួលស្គាល់សិទ្ធិស្របច្បាប់របស់រដ្ឋាភិបាលនោះទេ ។ បើទោះបីខ្ញុំជានាយករដ្ឋមន្ត្រី ក៏ខ្ញុំជាពលរដ្ឋម្នាក់ដែរ ដែលត្រូវការសិទ្ធិដើម្បីការពារខ្លួន "...(សារព័ត៌មានដើមអំពិល ឆ្នាំទី ៣ លេខ ២៦១ ថ្ងៃព្រហស្បតិ៍ ទី ១៣ ខែ សីហា ឆ្នាំ ២០០៩)"* ។

...សម្តេចតេជោបានប្រើពាក្យធ្ងន់ៗដោយនិយាយសំដៅទៅរកជនបរទេសថា... *"សូមកុំលេងស្មៀតចងដៃខ្ញុំអោយគេវៃ ។ ខ្ញុំមិនព្រមឡើយ ។ ពួកបរទេសទាំងឡាយល្មមដកខ្លួនទៅ"* ។ ...*"សម្តេចបានទាមទារអោយបរទេសទទួលស្គាល់សិទ្ធិរបស់សម្តេចក្នុងនាមជាពលរដ្ឋម្នាក់ ហើយជំរុញអោយពួកគេឈប់ប្រកាន់យកឥរិយាបទទទួលស្គាល់តែសិទ្ធិរបស់ពួកអ្នកប្រឆាំង ហើយបដិសេធសិទ្ធិស្របច្បាប់របស់អ្នកកាន់អំណាច ... តើអ្នកឯងទទួលស្គាល់ទេថាខ្ញុំជាពលរដ្ឋម្នាក់? ហេតុអ្វីបានជាខ្ញុំត្រូវបាត់បង់សិទ្ធិ? ...មិនមែនធ្វើនាយករដ្ឋមន្ត្រីត្រូវបាត់បង់សិទ្ធិឡើយ"... (សារព័ត៌មានរស្មីកម្ពុជា ឆ្នាំទី ១៧ លេខ ៤៩៧១ ថ្ងៃ ព្រហស្បតិ៍ ទី ១៣ ខែ សីហា ឆ្នាំ ២០០៩)* ។

សរុបសេចក្តីមក ការផ្សាយរបស់សារព័ត៌មានខ្មែរម្ចាស់ស្រុក រំលោភលើជំពូក ២ ស្តីពីការទទួលខុសត្រូវ នៃអ្នកសារព័ត៌មាន ត្រង់មាត្រា ៧ ចំណុច ៣ និងចំណុច ១១ : (រាយការណ៍មិនតាមហេតុការណ៍... កែបន្លំឯកសារ... បន្លំអោយគេយល់ខុស... ដើម្បីធ្វើអោយអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់...) ជាហេតុធ្វើអោយជនបរទេសដែលកំពុងស្នាក់នៅកម្ពុជាមានការជ្រួលច្របល់ចំពោះការផ្សាយខាងលើនេះ ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបជាព័ត៌មាន ដ៏ខ្ពង់ខ្ពស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩
**ជ. ប្រធាននាយកដ្ឋាន**

ទិត្យ កល្យាណី

Press
15/VIII